ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ..................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១២
## និងទិសដៅការងារឆ្នាំ២០១៣ របស់ធនាគារជាតិនៃកម្ពុជា
### នៅខេត្តកំពង់ចាម ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៣

សូមគោរព :

- គណៈអធិបតី
- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !

នៅពេលនេះ សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១២ និងទិសដៅការងារឆ្នាំ២០១៣ របស់ធនាគារជាតិនៃកម្ពុជាយើង បានឈានដល់ទីបញ្ចប់ប្រកបដោយជោគជ័យក្រោមបរិយាកាសសប្បាយរីករាយនិងស្និទ្ធស្នាលបំផុត ។ ជារួម ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា សន្និបាតយើងបានផ្តល់ជូនខ្លឹមសារសំខាន់ៗ ហើយថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិកយើងទាំងអស់ពិតជាក្តាប់បាននូវខ្លឹមសារ និងទិសដៅការងារដែលត្រូវយកទៅអនុវត្តបន្តនៅពេលខាងមុខនេះ ។ ហើយក្រៅពីនេះ ខ្ញុំជឿជាក់ថា មន្ត្រីបុគ្គលិកយើងក៏បានស្វែងយល់ពីការអភិវឌ្ឍរីកចម្រើននៃហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គមជារូបវន្ត នៅក្នុងខេត្តកំពង់ចាមនេះផងដែរ ។ ទាំងនេះសុទ្ធតែជាគំនិតនិងទស្សនៈជំនួយសម្រាប់មន្ត្រីបុគ្គលិកយើងទាំងអស់គ្នា យកទៅបំពេញការងារប្រកបដោយបញ្ញាញាណនិងមានប្រសិទ្ធភាពចំពោះការងារថែមទៀត ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោក លោកស្រី ដែលបានធ្វើបទអន្តរាគមន៍និងផ្តល់អនុសាសន៍ល្អៗជូនអង្គសន្និបាតយើង ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិកទាំងអស់ ដែលបានអញ្ជើញចូលរួម និងខិតខំយកចិត្តទុកដាក់ស្តាប់ខ្លឹមសារសំខាន់ៗនៃអង្គសន្និបាត ដើម្បីយកទៅបំពេញភារកិច្ច ឱ្យកាន់តែទទួលបានជោគជ័យល្អប្រសើរថែមទៀត ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

ក្នុងរយៈពេលមួយថ្ងៃកន្លះ ខ្ញុំបានកត់សម្គាល់ឃើញថា អង្គសន្និបាតរបស់យើងបានប្រព្រឹត្តទៅយ៉ាងសកម្ម ដោយផ្តោតលើចំណុចសំខាន់ៗ ដូចតទៅ ៖



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**១/- សមិទ្ធផលការងាររបស់ធនាគារជាតិនៃកម្ពុជា និងស្ថានភាពសេដ្ឋកិច្ចជាតិ** : ខ្លឹមសារសំខាន់ៗនៃសមិទ្ធផលការងាររបស់ធនាគារជាតិនៃកម្ពុជា លោកស្រី ងួន សុខា បានជម្រាបជូនអង្គសន្និបាតរួចហើយ ដូចជា សមិទ្ធផលនៃការដឹកនាំនិងគ្រប់គ្រងនយោបាយរូបិយវត្ថុ ការត្រួតពិនិត្យនិងពង្រឹងសុវត្ថិភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ការគ្រប់គ្រងការវិនិយោគទុនបម្រុងអន្តរជាតិ ការគ្រប់គ្រងនិងពង្រឹងសុវត្ថិភាពប្រតិបត្តិការការងារធនាគារកណ្តាល ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការងារទំនាក់ទំនងអន្តរជាតិ ជាដើម ។ សមិទ្ធផលទាំងអស់នេះពិតជាបានរួមចំណែកក្នុងការអភិវឌ្ឍប្រព័ន្ធធនាគារឱ្យប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព រក្សាបាននូវស្ថិរភាពថ្លៃ និងបានរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅគាំទ្រចីរភាពនៃកំណើនសេដ្ឋកិច្ច ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ។

ដោយសារវិបត្តិទីផ្សារហិរញ្ញវត្ថុអន្តរជាតិ និងសេដ្ឋកិច្ចពិភពលោក នៅតែបន្តជះឥទ្ធិពលយ៉ាងខ្លាំងដល់ស្ថានភាពសេដ្ឋកិច្ចក្នុងតំបន់ គួបផ្សំនឹងការអនុវត្តគោលនយោបាយរបស់អាជ្ញាធរមិនទាន់មានភាពពិតប្រាកដប្រជាផងនោះ នៅឆ្នាំ២០១៣នេះ សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថានឹងមានកំណើន ៧% ប្រហាក់ប្រហែលនឹងឆ្នាំមុនដែរ ។ កំណើននេះ ទ្រទ្រង់ដោយវិស័យកសិកម្ម ទេសចរណ៍ កាត់ដេរ និង វិនិយោគផ្ទាល់បរទេស ។

ដើម្បីសម្រេចបាននូវគោលដៅចីរភាពនៃកំណើន ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល អាជ្ញាធរពាក់ព័ន្ធត្រូវរួមចំណែកបន្តពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងអនុវត្តគោលនយោបាយគាំទ្រមួយចំនួនទៀត ដូចជា ការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ដោយផ្សារភ្ជាប់នឹងទីផ្សារជាដើម ។ ចំពោះវិស័យធនាគារ ខ្ញុំសូមលើកឡើងនូវមតិខ្លះៗសម្រាប់ឱ្យមន្ត្រីបុគ្គលិកទាំងនៅទីស្នាក់ការកណ្តាល និងនៅសាខារាជធានី-ខេត្ត ជ្រាបពីអ្វីដែលធនាគារជាតិនៃកម្ពុជាត្រូវធ្វើនាពេលអនាគត ដូចតទៅ ៖

**២/- ការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច** : គឺជាការងារសំខាន់របស់យើងក្នុងការពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ និងសុវត្ថិភាពធនាគារកណ្តាល ។ ខ្ញុំសូមឯកភាពតាមមតិ លោក ហ៊ុយ ណារី ដែលបានជម្រាបជូនអង្គសន្និបាតយើង ។ ដើម្បីបន្តអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យថែមទៀត ខ្ញុំស្នើសុំឱ្យអគ្គាធិការដ្ឋាន បន្តចុះតាមដានការអនុវត្តតាមអនុសាសន៍ដែលបានលើកឡើង និងរៀបចំយន្តការវាយតម្លៃហានិភ័យប្រតិបត្តិការតាមផ្នែក និងពង្រឹងការងារអធិការកិច្ច ទាំងនៅទីស្នាក់ការកណ្តាល និងសាខារាជធានី-ខេត្ត បន្តទៀត ជាពិសេស ត្រូវសហការជាមួយនាយកដ្ឋានគណនេយ្យនិងនាយកដ្ឋានពាក់ព័ន្ធផ្សេងទៀត ដើម្បីរៀបចំ ៖ *១)*- លំហូរការងារ (workflows) *២)*- កំណត់មុខងារនិងភារកិច្ចអ្នកប្រើប្រាស់ (Function Users & Passwords) *៣)*-

រៀបចំការណែនាំពីរបៀបប្រើប្រាស់ប្រព័ន្ធ User guides និងរវាងទីស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្ត ។

ដើម្បីអនុវត្តការងារនេះប្រកបដោយប្រសិទ្ធភាព ទាមទារឱ្យមន្ត្រីបុគ្គលិកយើងត្រូវពង្រឹងស្មារតីទទួលខុសត្រូវចំពោះការងារ គោរពវិន័យ និងខិតខំអភិវឌ្ឍខ្លួនឱ្យដើរទាន់ការប្រែប្រួលនៃស្ថានភាពការងារបច្ចុប្បន្ន ជាពិសេស ស្របតាមស្តង់ដារអន្តរជាតិ ។ ខ្ញុំសូមបញ្ជាក់ថាការងារនេះមានសារៈសំខាន់ណាស់សម្រាប់វាយតម្លៃពីភាពរឹងមាំ សុវត្ថិភាព និងប្រសិទ្ធភាពនៃប្រតិបត្តិការធនាគារជាតិនៃកម្ពុជា ស្របតាមគោលការណ៍អភិបាលកិច្ចល្អ ។ ចំណុចដែលខ្ញុំបានលើកឡើងនេះ គឺទាក់ទងនឹងប្រសិទ្ធភាពប្រតិបត្តិការ និងសុវត្ថិភាពធនាគារកណ្តាលទាំងអស់ ។

**៣/- ការពង្រឹងនិងអភិវឌ្ឍប្រព័ន្ធធនាគារ** : លោក គិម វ៉ាដា បានជម្រាបជូនអង្គសន្និបាតរួចហើយ អំពីការរីកចម្រើននៃវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ជាពិសេស អំពីវិធីសាស្ត្រថ្មីៗដែលយើងអនុវត្ត ដើម្បីពង្រឹងសុខភាពនិងសុវត្ថិភាពប្រព័ន្ធធនាគារនៅកម្ពុជា ។ សុវត្ថិភាពនៃប្រព័ន្ធធនាគារ គឺជាការងារអាទិភាពដែលយើងត្រូវពង្រឹងជាប់ជាប្រចាំ តាមរយៈការដាក់ចេញនូវវិធានការទាំងផ្នែកម៉ាក្រូនិងមីក្រូប្រុងប្រយ័ត្ន និងត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ជាពិសេស គ្រឹះស្ថានណាដែលមានហានិភ័យជាប្រព័ន្ធ ។ ដើម្បីអនុវត្តការងារនេះឱ្យបានសម្រេច ធនាគារជាតិនៃកម្ពុជាបានធ្វើបច្ចុប្បន្នកម្មប្រព័ន្ធវិភាគរបាយការណ៍ COBRA ទៅជាប្រព័ន្ធត្រួតពិនិត្យលើឯកសារ (Off-Site Surveillance System) វិញ ។

នេះជា ប្រព័ន្ធត្រួតពិនិត្យថ្មីដែលមានយុទ្ធសាស្ត្រត្រួតពិនិត្យផ្អែកលើមូលដ្ឋានហានិភ័យ (Risk-based) ដែលផ្តោតការត្រួតពិនិត្យជាសំខាន់ទៅលើទិន្នន័យហិរញ្ញវត្ថុ ការបញ្ជូនរបាយការណ៍តាមប្រព័ន្ធ internet ការវិភាគស្ថានភាពហិរញ្ញវត្ថុនិងហានិភ័យ សាវតារធនាគារ និងវិធានការកែតម្រូវជាបន្ទាន់ ។ ជាមួយគ្នានេះ យើងក៏ត្រូវបន្តលើកកម្ពស់សមត្ថភាពមន្ត្រីត្រួតពិនិត្យ និងបញ្ញត្តិករ និងរៀបចំវិធីសាស្ត្រនៃការត្រួតពិនិត្យដោយផ្អែកលើទស្សនៈអនាគត (Forward-looking) និងការត្រួតពិនិត្យរួបសរុប (Consolidated) បន្ថែមលើយន្តការត្រួតពិនិត្យបច្ចុប្បន្ន ក្នុងខណៈពេលនៃការបង្កើតទីផ្សារមូលបត្រនិងទីផ្សារទុនថ្មីៗកន្លងទៅនេះ ។

ចំពោះវិស័យមីក្រូហិរញ្ញវត្ថុវិញ ក្រៅពីការពង្រឹងការងារត្រួតពិនិត្យជាប់ជាប្រចាំនោះ ត្រូវរៀបចំផែនការសកម្មភាពឱ្យស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែង ដូចជា ១/- បង្កើនប្រសិទ្ធភាពតួនាទីការិយាល័យឥណទាន ២/- កែលម្អក្របខ័ណ្ឌច្បាប់ និងប្រព័ន្ធ គ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៣/- បង្កបរិយាកាសប្រកួតប្រជែង លើអត្រាការប្រាក់ សេវា និងផលិតផលហិរញ្ញវត្ថុ និង ៤/-

ពង្រីកលទ្ធភាពប្រើប្រាស់ឥណទាន
ចំពោះប្រជាជនដែលមានចំណូលទាបនៅតំបន់ជនបទបន្ថែមទៀត ។

ទន្ទឹមពេលនេះ ខ្ញុំសូមជម្រាបផងដែរថា ខណៈដែលប្រទេសអភិវឌ្ឍន៍កំពុងប្រឈម និងវិបត្តិហិរញ្ញវត្ថុអន្តរជាតិនេះ អាជ្ញាធរនៃស្ថាប័នហិរញ្ញវត្ថុអន្តរជាតិបានតម្រូវឱ្យធនាគារកណ្តាល នៃប្រទេសក្នុងតំបន់នោះ អនុវត្តវិធានការដូចខាងក្រោម ៖

*១-* កែលម្អក្របខ័ណ្ឌបទប្បញ្ញត្តិ ដើម្បីពង្រឹងការគ្រប់គ្រងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានហានិភ័យជាប្រព័ន្ធ (SIFIs) ឱ្យកាន់តែស៊ីជម្រៅថែមទៀត ។ បទប្បញ្ញត្តិសម្រាប់ គ្រប់គ្រងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានហានិភ័យជាប្រព័ន្ធ (SIFIs) ត្រូវមានលក្ខណៈ ស៊ីជម្រៅ និងមានលក្ខណៈប្រុងប្រយ័ត្នខ្ពស់ ក្នុងនោះក៏ត្រូវយកចិត្តទុកដាក់គ្រប់គ្រងដល់បណ្តា ក្រុមហ៊ុនធានារ៉ាប់រងធំៗផងដែរ ។

*២-* កំណត់និងរៀបចំវិធានការគ្រប់គ្រងធនាគារធំៗ ក្នុងស្រុករបស់ខ្លួនដែលមានហានិ ភ័យ ជាប្រព័ន្ធ (D-SIFIs) ដោយកំណត់ថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងស្រុកធំៗ ណាខ្លះ ដែលមានហានិភ័យជាប្រព័ន្ធ និងចាំបាច់ត្រូវរៀបចំវិធានការប្រុងប្រយ័ត្នឱ្យបាន ហ្មត់ចត់ ដើម្បី កាត់បន្ថយឥទ្ធិពលជាអវិជ្ជមានជាយថាហេតុ នៅពេល ធនាគារធំៗនោះដួល រលំ ។

*៣-* ការកែទម្រង់ក្របខ័ណ្ឌបទប្បញ្ញត្តិ : ត្រូវបន្តអនុវត្តដើម្បីពង្រឹងភាពរឹងមាំនិង អភិបាលកិច្ចល្អរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ទាំងផ្នែកមីក្រូប្រុងប្រយ័ត្ននិងផ្នែកម៉ាក្រូ ប្រុងប្រយ័ត្នតាមរយៈការខិតខំអនុវត្តតាមគោលការណ៍គ្រឹះថ្មីៗរបស់គណៈកម្មាធិការទីក្រុង បាសែល និងរៀបចំឱ្យមានវិធានការសម្រាប់ទប់ទល់និងដោះស្រាយវិបត្តិហិរញ្ញវត្ថុ ។

*៤-* នៅប្រទេសកម្ពុជាវិញ ដើម្បីការពារហានិភ័យក្នុងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ យើងបានរៀបចំនូវ ក្របខ័ណ្ឌបទប្បញ្ញត្តិ ប្រព័ន្ធប្រកាសអាសន្នជាមុន វិធានការការពារ គ្រប់គ្រងនិងដោះស្រាយវិបត្តិ ស្របតាមគោលការណ៍គ្រឹះរបស់គណៈកម្មាធិការទីក្រុងបាសែល ក្នុងក្របខ័ណ្ឌម៉ាក្រូប្រុងប្រយ័ត្ននិងមីក្រូប្រុងប្រយ័ត្ន ។ ទន្ទឹមគ្នានេះ យើងត្រូវបន្តបណ្តុះបណ្តាល មន្ត្រីត្រួតពិនិត្យនិងបញ្ញត្តិករជាប់ជាប្រចាំ ដើម្បីវាយតម្លៃហានិភ័យ បញ្ហាប្រឈម និងការលើក ជាវិធានការសម្រាប់ពង្រឹងស្ថិរភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ។ បច្ចុប្បន្ននេះ យើងកំពុង បណ្តុះបណ្តាលសមត្ថភាពក្រុមការងារស្ថិរភាពហិរញ្ញវត្ថុរបស់យើងបណ្តើរ ដើម្បីហាត់រៀន ធ្វើការងារនេះបណ្តើរៗ ។

**៤/- ការងារអគ្គបេឡា :** លោកស្រី អ៊ុច សុខុម បានជម្រាបជូនអង្គសន្និបាតពីសមិទ្ធផល នៃការគ្រប់គ្រងបេឡាប្រតិបត្តិការ ការផ្គត់ផ្គង់ធនបត្រ ការរក្សាសុវត្ថិភាពឃ្លាំងទ្រព្យសម្បត្តិ

និងការដឹកជញ្ជូនធនបត្រ ដែលមានការរីកចម្រើនយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ បន្ទាប់ពីយើងបានកែលម្អសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តឡើងវិញ ។ ការងារឃ្លាំងបេឡាគឺជាការងារបច្ចេកទេស ទាក់ទងនឹងការបោះផ្សាយ ការគ្រប់គ្រងឃ្លាំងបេឡា និងការតាមដានបរិមាណរូបិយវត្ថុទូទៅ នៅក្នុងសេដ្ឋកិច្ច ។ ដូច្នេះ ការងារនេះទាមទារនូវចំណេះដឹងទាំងផ្នែកជំនាញ ស្មារតីទទួលខុសត្រូវ ភាពស្មោះត្រង់ និងការតស៊ូអត់ធ្មត់ចំពោះការងារ ។ ដើម្បីបង្កើនប្រសិទ្ធភាពការងារបន្ថែមទៀត តម្រូវឱ្យមន្ត្រីទាំងអស់បង្កើនសមត្ថភាពគ្រប់គ្រង និងរក្សាទុកសន្និធិតាមលក្ខណៈបច្ចេកទេស ។

ចំពោះការពង្រឹងវិន័យការងារ ខ្ញុំក៏សូមឯកភាពតាមមតិណែនាំរបស់ ឯកឧត្តម ថា យ៉ាវ ផងដែរ ។ ការថែរក្សាសុវត្ថិភាពឃ្លាំងទ្រព្យសម្បត្តិជាតិ តម្រូវឱ្យមន្ត្រីគោរពវិន័យការងារមានភាពស្មោះត្រង់ និងមានការទទួលខុសត្រូវច្បាស់លាស់ ក្នុងការទុកដាក់និងគ្រប់គ្រងទ្រព្យសម្បត្តិ តាមលក្ខណៈបច្ចេកទេស ។ ខ្ញុំស្នើសុំឱ្យគ្រប់អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាទាំងអស់ ត្រូវពង្រឹងវិន័យការងារ និងចាត់តាំងឱ្យមានអ្នកប្រចាំការនៅកន្លែងការងារនៅរាល់ថ្ងៃចុងសប្តាហ៍និងថ្ងៃបុណ្យ ដើម្បីថែរក្សាការពារនូវសុវត្ថិភាពទ្រព្យសម្បត្តិយើង កុំឱ្យបាត់បង់ ឬបង្ការក្រែងមានហេតុការណ៍ណាមួយកើតឡើងដោយចៃដន្យ អាចដោះស្រាយបានទាន់ពេលវេលា ។

**៥/- ចំពោះការងារគណនេយ្យ IT និងប្រព័ន្ធទូទាត់** : ដូច លោក អ៊ូ ចាន់តារា បានបញ្ជាក់ហើយថា ការងារនេះ មានការវិវត្តរីកចម្រើនយ៉ាងខ្លាំង ហើយមានការលំបាកខ្លាំងណាស់ដែរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប៉ុន្តែ យើងអាចជំនះបានការលំបាកនោះបានតាមរយៈរបៀបការរៀនបណ្តើរ-ធ្វើការងារបណ្តើរ ។ ជាបទពិសោធន៍ល្អ ការអនុវត្តប្រព័ន្ធ Flexcube កន្លងមក បានបង្រៀនយើងពីរបៀបធ្វើការងារថ្មី និងមានលក្ខណៈវិទ្យាសាស្ត្រជាងមុន ពោលគឺបានប្តូរពីរបៀប manual ទៅប្រើប្រព័ន្ធកុំព្យូទ័រទាំងអស់ (computerization based) ។ ខ្ញុំគិតថាការងារនេះ ពេលចាប់ផ្តើមដំបូងគឺលំបាកហើយ ប៉ុន្តែក្រោយមកយើងអនុវត្តបានស្រួលវិញ ។ យើងបានបំពាក់ប្រព័ន្ធនេះ ទាំងនៅទីស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្ត និងរៀបចំបទប្បញ្ញត្តិ គ្រប់គ្រងប្រតិបត្តិការទូទាត់និងផាត់ទាត់តាមប្រព័ន្ធ IT ក្នុងបំណងចែករំលែកព័ត៌មានហិរញ្ញវត្ថុ និងលំហូរការងារឱ្យទាន់គ្នាក្នុងពេលតែមួយ (real time) ចំពោះប្រតិបត្តិការតែមួយដូចគ្នា ។ ការងារនេះ យើងកំពុងដំណើរការស្រួលហើយ ។

ការងារគ្រប់គ្រងប្រព័ន្ធទូទាត់ ជាតួនាទីសំខាន់របស់ធនាគារជាតិនៃកម្ពុជា ហើយក៏ជាការងារថ្មីដែលយើងទើបតែដាក់ឱ្យដំណើរការ កាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ កន្លងមកនេះ សម្រាប់ទូទាត់តែមូលប្បទានបត្រប៉ុណ្ណោះ ។ បច្ចុប្បន្ននេះ ប្រតិបត្តិការទូទាត់សងប្រាក់មានដូចជា មូលប្បទានបត្រ ការបញ្ជាទូទាត់ Credit Card, Debit Card, ATM, Easy Cash

និងការទូទាត់តាមទូរសព្ទចល័តជាដើម កំពុងមានការរីកចម្រើនយ៉ាងខ្លាំងនៅកម្ពុជា ទាំងផ្នែកបណ្តាញ សេវា និងផលិតផលហិរញ្ញវត្ថុ ទន្ទឹមនឹងការដាក់ឱ្យដំណើរការទីផ្សារហ៊ុន និងទីផ្សារសញ្ញាបណ្ណ នាពេលថ្មីៗនេះ ក៏មានឧបករណ៍ហិរញ្ញវត្ថុថ្មីៗថែមទៀត ដូចជា សញ្ញាបណ្ណ និងសន្លឹកហ៊ុន កើតឡើងផងដែរ ។ យើងបានបំពាក់ប្រព័ន្ធ Client Module សម្រាប់ប្រព័ន្ធទូទាត់ដែលមានលក្ខណៈមជ្ឈការ និងបណ្តុះបណ្តាលមន្ត្រីជំនាញពីវិធីប្រើប្រាស់ប្រព័ន្ធនេះ ដល់ធនាគារជាសមាជិកសភាផាត់ទាត់ ។

ដើម្បីអនុវត្តការងារនេះឱ្យបានកាន់តែប្រសើរថែមទៀត ខ្ញុំស្នើសុំឱ្យនាយកដ្ឋានគណនេយ្យសហការជាមួយអគ្គាធិការដ្ឋាន នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និងនាយកដ្ឋានពាក់ព័ន្ធ បន្តបណ្តុះបណ្តាលមន្ត្រីជំនាញនៅសាខារាជធានី-ខេត្តយើង ដើម្បីណែនាំពីរបៀបប្រើប្រាស់ (User guides) ការប្រើប្រាស់ប្រព័ន្ធទូទាត់ផ្ទាល់ ជាលក្ខណៈអន្តរធនាគារ រវាងធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងភ្នាក់ងារប្រតិបត្តិផ្សេងទៀត និងជាពិសេស រៀបចំបោះពុម្ពសៀវភៅក្រហមភាគ២ សម្រាប់ធ្វើជា guideline រួមក្នុងការបណ្តុះបណ្តាលនិងអនុវត្តការងារជាក់ស្តែង ។

**៦/- ការពង្រឹងការប្រើប្រាស់ប្រាក់រៀល** : នេះជាយន្តការការងារផង និងជាគោលនយោបាយរបស់យើងផង ហើយការងារនេះ មានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១- ២០២០ របស់រាជរដ្ឋាភិបាល ។ បញ្ហាដុល្លាររូបនីយកម្មនៅក្នុងសេដ្ឋកិច្ចនៃប្រទេសកម្ពុជា មិនមែន កើតឡើងដោយឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលទេ គឺកើតឡើងដោយសារកត្តាប្រវត្តិសាស្ត្រ បន្សល់ទុក និងការបាត់បង់ជំនឿទុកចិត្តមកលើរូបិយវត្ថុជាតិ ។ បញ្ហានេះបានក្លាយទៅជា បញ្ហាម៉ាក្រូសេដ្ឋកិច្ចជាតិ តម្រូវឱ្យយើងរួមគ្នាដោះស្រាយដោយសន្សឹមៗ និងប្រុងប្រយ័ត្នបំផុត ។ កន្លងមក ធនាគារជាតិនៃកម្ពុជា រួមជាមួយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម បានអនុវត្តវិធានការពង្រឹងការប្រើប្រាស់ប្រាក់រៀល ទទួលបានជោគជ័យគួរឱ្យកត់សម្គាល់ ដូចជា ការបើកប្រាក់ខែជូនមន្ត្រីរាជការនិងកងកម្លាំងប្រដាប់អាវុធ ការបង់ពន្ធ និងការទូទាត់ ថ្លៃទឹក-ភ្លើង ដោយធ្វើឡើងជាប្រាក់រៀល ។

បច្ចុប្បន្ន យើងសង្កេតឃើញថា និន្នាការនៃការប្រើប្រាស់ប្រាក់រៀលបានកើនឡើងយ៉ាងទូលំទូលាយនៅក្នុងសកម្មភាពសេដ្ឋកិច្ច ។ ការកើនឡើងនេះអាចឆ្លុះបញ្ចាំងតាមរយៈសូចនាករសេដ្ឋកិច្ចមួយចំនួន ដូចជា កំណើនរូបិយវត្ថុទូទៅ (M2) បានកើនឡើងជារៀងរាល់ឆ្នាំ និងការបញ្ចាំងខ្សែភាពយន្តស្តីពី **"ខ្ញុំស្រឡាញ់លុយរៀល"** កន្លងមក ឃើញថា សាធារណជនភាគច្រើនបានគាំទ្រ និងយល់ពីតម្លៃនិងសារៈប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀលនៅក្នុងសេដ្ឋកិច្ចនិងជីវភាពប្រចាំថ្ងៃ ។ ទន្ទឹមនឹងនេះ ក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រជំរុញការប្រើប្រាស់ប្រាក់រៀលត្រូវបានបង្កើតឡើង ដើម្បីធ្វើរៀបចំផែនការយុទ្ធសាស្ត្រជំរុញការ

ប្រើប្រាស់ប្រាក់រៀលនេះ ។ ដើម្បីជាធាតុចូលក្នុងការរៀបចំ ខ្ញុំស្នើសុំឱ្យក្រុមការងារយើង ត្រូវពិចារណាលើបុរេលក្ខខណ្ឌចាំបាច់មួយចំនួន ដូចជា ៖

- បញ្ហាស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាមួយនឹងការធ្វើបដិដុល្លារូប– នីយកម្ម
- បញ្ហាស្ថិរភាពអត្រាប្តូរប្រាក់និងអតិផរណាជាមួយនឹងការធ្វើបដិដុល្លារូបនីយកម្ម
- ឆន្ទៈនយោបាយនិងក្របខ័ណ្ឌច្បាប់ និង
- ការចូលរួមសហការពីភាគីពាក់ព័ន្ធ និងការប្រើប្រាស់កម្លាំងសរុបជាដើម ក្នុងការ រួមចំណែកធ្វើបដិដុល្លារូបនីយកម្មនេះ ។ ហើយការរៀបចំផែនការយុទ្ធសាស្ត្រនេះ ត្រូវសិក្សា អំពីចំណុចខ្លាំងនិងចំណុចខ្សោយ បញ្ហាប្រឈមនិងដំណោះស្រាយ លំដាប់លំដោយ និង អាទិភាពការងារ ជាពិសេស ត្រូវគិតពីផលប៉ះពាល់នានាចំពោះនយោបាយនិងសេដ្ឋកិច្ច ។ ខ្ញុំជឿជាក់ថា ក្រុមការងារយើងបានសិក្សាពីបទពិសោធន៍នៃប្រទេសជិតខាងមួយចំនួនហើយ ។

**៧/- ការងារគ្រប់គ្រងនិងបណ្តុះបណ្តាលមន្ត្រីបុគ្គលិក :** ជាការងារសំខាន់សម្រាប់ស្ថាប័ននិងប្រទេសជាតិ ព្រោះការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាកំណត់ជោគជ័យនៃការងាររបស់យើងលើគ្រប់ផ្នែក ។ យើងត្រូវបណ្តុះបណ្តាលមន្ត្រីលើផ្នែកជំនាញឯកទេសកម្ម ដើម្បីកសាងកម្លាំងបន្តវេន និងបន្តនិរន្តរភាពនិងស្ថិរភាពការងាររបស់យើងនៅពេលអនាគត ខណៈដែលថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិករបស់យើង កំពុងចូលនិវត្តន៍ជាបណ្តើរៗ ។ ការបណ្តុះបណ្តាលរបស់យើងមានគ្រប់រូបភាព ទាំងនៅក្នុងនិងក្រៅប្រទេស លើផ្នែកជំនាញឯកទេសកម្មនិងផ្នែកគុណធម៌ ។

ជាលទ្ធផល យើងទទួលបានមន្ត្រីដែលមានសមត្ថភាពជំនាញជាបន្តបន្ទាប់ និងបានជួយការងាររបស់យើងសម្រេចបានសមិទ្ធផលល្អប្រសើរ ។ ថ្មីៗនេះ យើងទើបតែបានបង្កើតក្រុមអ្នកសេដ្ឋកិច្ចវ័យក្មេង សម្រាប់ពិគ្រោះយោបល់និងធ្វើការជាមួយនឹងតំណាង IMF ប្រចាំនៅកម្ពុជា និងជំនាញការបរទេសនៅធនាគារជាតិនៃកម្ពុជា ។

បច្ចុប្បន្ន យើងមានយន្តការបណ្តុះបណ្តាលជាប់ជាប្រចាំ ទាំងក្នុងនិងក្រៅប្រទេស ។ ក្នុងប្រទេស យើងបានរៀបចំក្រោមរូបភាពនៃការផ្ទេរនិងចែករំលែកចំណេះដឹង និងវគ្គបណ្តុះបណ្តាលផ្សេងៗ ។ នៅក្រៅប្រទេស យើងមានដៃគូអភិវឌ្ឍក្នុងតំបន់និងអន្តរជាតិ ដូចជា មជ្ឈមណ្ឌលបណ្តុះបណ្តាល IMF, ADB, WB, មជ្ឈមណ្ឌល SEACEN, ASEAN, ASEAN+3 និងមជ្ឈមណ្ឌល Toronto និងការបណ្តុះបណ្តាលជាលក្ខណៈទ្វេភាគីជាមួយធនាគារកណ្តាលនៅតំបន់អឺរ៉ុប ដូចជា ធនាគារកណ្តាលបារាំង អាល្លឺម៉ង់ និងលុចហ្សំបួរ និងនៅតំបន់អាស៊ីមានធនាគារកណ្តាលថៃ ម៉ាឡេស៊ី កូរ៉េ វៀតណាម ឡាវ និងម៉ុងហ្គោលីជាដើម ។

ដើម្បីបន្តអនុវត្តការងារបណ្តុះបណ្តាលឱ្យកាន់តែល្អប្រសើរថែមទៀត ខ្ញុំស្នើសុំឱ្យអគ្គលេខាធិការដ្ឋាន ជាពិសេស នាយកដ្ឋានបុគ្គលិក ត្រូវរៀបចំយន្តការ និងកម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំ ហើយសូមឱ្យមន្ត្រីបុគ្គលិកយើងខិតខំសិក្សារៀនសូត្របន្ថែម ដើម្បីដើរឱ្យទាន់សភាពការណ៍រីកចម្រើននៃសេដ្ឋកិច្ច និងមានភាពម្ចាស់ការក្នុងការគ្រប់គ្រងធនាគារជាតិនៃកម្ពុជា និងប្រព័ន្ធធនាគារនៅកម្ពុជាឱ្យកាន់តែរីកចម្រើនថែមទៀត។

**៨/- ការពង្រឹងប្រតិបត្តិការជាមួយសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត** : ដូចរបាយការណ៍របស់ ឯកឧត្តម ស៊ុំ សន្និសិទ្ធ អគ្គលេខាធិការ បានបញ្ជាក់ថា សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត គឺជាឃ្លាំងប្រាក់សម្រាប់ផ្ទុកទ្រព្យសម្បត្តិរបស់រដ្ឋ និងជាធនាគាររបស់រដ្ឋ ដើម្បីអនុវត្តមុខងារនិងភារកិច្ចជូនមន្ទីរ-អង្គភាពរបស់រដ្ឋ ។ ដូច្នេះ ការងារសំខាន់ៗរបស់យើង គឺការគ្រប់គ្រងសាច់ប្រាក់ ការបើកគណនីនិងគ្រប់គ្រងសេវាគណនីរបស់រដ្ឋ សំដៅជួយសម្រួលចរាចរសាច់ប្រាក់ ប្រតិបត្តិការផ្ទេរសាច់ប្រាក់ ការទូទាត់ពាណិជ្ជកម្ម ការបង់ពន្ធអាករ និងការបើកប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទូទាំងប្រទេស ។

ការងារនេះគឺជាការងារអាទិភាពរបស់យើង ហើយក៏ជាយន្តការជំរុញការប្រើប្រាស់ប្រាក់រៀលរបស់រាជរដ្ឋាភិបាលផងដែរ ។ ដូច្នេះ ខ្ញុំសូមស្នើសុំឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ត្រូវពង្រឹងការអនុវត្តមុខងារនិងភារកិច្ចរបស់ខ្លួន និងសហការជាមួយអាជ្ញាធរ ពាក់ព័ន្ធក្នុងដែនដីរដ្ឋបាល ដើម្បីសម្រួលការដាក់ឱ្យចរាចរប្រាក់រៀលឱ្យប្រព្រឹត្តទៅដោយរលូន និងកាន់តែទូលំទូលាយថែមទៀត ។

**៩/- ការងារសហប្រតិបត្តិការអន្តរជាតិ** : ការងារនេះមានសារៈសំខាន់ណាស់សម្រាប់ធនាគារជាតិនៃកម្ពុជា ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការមិត្តភាព និងផ្លាស់ប្តូរបទពិសោធន៍ក្នុងការដឹកនាំគោលនយោបាយរូបិយវត្ថុ និងការពង្រឹងប្រតិបត្តិការធនាគារកណ្តាល ។ កិច្ចសហប្រតិបត្តិការអន្តរជាតិ យើងមានការរីកចម្រើនយ៉ាងខ្លាំង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ នៅខែវិច្ឆិកា ឆ្នាំ២០១២នេះ ប្រទេសកម្ពុជាបាន ធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន ហើយកាលពីចុងខែមីនា កន្លងទៅនេះ ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី៨ កិច្ចប្រជុំថ្នាក់ទេសាភិបាលរងអាស៊ាន អាស៊ាន+៣ និងកិច្ចប្រជុំពាក់ព័ន្ធមួយចំនួនទៀត ។

តាមរយៈកិច្ចសហប្រតិបត្តិការនេះ ធនាគារជាតិនៃកម្ពុជា : (១). ពង្រឹងកិច្ចសហប្រតិបត្តិការជាមិត្តភាពជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជា IMF, ADB, WB និងធនាគារកណ្តាលក្នុងតំបន់និងពិភពលោក (២). លើកកម្ពស់កិត្យានុភាព និងតួនាទីធនាគារជាតិនៃកម្ពុជានៅក្នុងតំបន់និងឆាកអន្តរជាតិ (៣). ជំរុញការធ្វើសមាហរណកម្មវិស័យធនាគារនៅកម្ពុជាចូលទៅក្នុងតំបន់និងពិភពលោក និង (៤). ធ្វើជាវេទិកាថ្នាក់តំបន់សម្រាប់ធ្វើការបណ្តុះបណ្តាលឯកទេសកម្ម

ដល់មន្ត្រីជំនាញ និងផ្លាស់ប្តូរយោបល់ពីការងារគ្រប់គ្រងធនាគារកណ្តាល និងការដឹកនាំនយោបាយរូបិយវត្ថុ ឆ្ពោះទៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជាតិនិងតំបន់ ។

ខ្ញុំស្នើសុំឱ្យមន្ត្រីបុគ្គលិករបស់យើងបន្តពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគីជាមួយប្រទេសជាមិត្តបន្ថែមទៀត ។

**- គណៈអធិបតី**

**- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ខ្លឹមសារដែលខ្ញុំបានលើកឡើងខាងលើនេះ សុទ្ធតែជាការងាររបស់ធនាគារជាតិនៃកម្ពុជាដែលយើងត្រូវអនុវត្តចំពោះមុខ រយៈពេលមធ្យមនិងវែងនៅពេលអនាគត ដើម្បីពង្រឹងប្រព័ន្ធធនាគារទាំងមូលឱ្យប្រព្រឹត្តទៅដោយរលូននិងមានសុវត្ថិភាព ។ មតិដែលខ្ញុំបានលើកឡើងខាងលើនេះខ្លីៗទេ បើសិនចង់ដឹងលម្អិតបន្ថែមទៀត សូមពិនិត្យក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់យើងបន្ថែមទៀត ។ ខ្ញុំសង្ឃឹមថា លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញាទាំងអស់ នឹងបន្តការខិតខំប្រឹងប្រែងអនុវត្តទិសដៅការងារ និងភារកិច្ចទាំងឡាយឱ្យសម្រេចបានជោគជ័យ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅរួមចំណែកពង្រឹងប្រព័ន្ធធនាគារ និងអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ឱ្យមានការរីកចម្រើនប្រកបដោយចីរភាព ។

មុននឹងបញ្ចប់ ខ្ញុំសូមផ្តាំផ្ញើនូវមតិមួយចំនួនដូចខាងក្រោម ៖

១/- ត្រូវយកស្មារតីនៃអង្គសន្និបាតរបស់យើងទៅបន្តផ្សព្វផ្សាយ នៅតាមនាយកដ្ឋាននិងអង្គភាពរៀងៗខ្លួន នូវខ្លឹមសារនិងអនុសាសន៍ល្អៗ ដើម្បីអនុវត្តចំពោះការងារប្រចាំថ្ងៃឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត

២/- សូមមន្ត្រីបុគ្គលិករបស់យើងបន្តរក្សានូវស្មារតីសាមគ្គីគ្នាជាប្រពៃណីដើម្បីបុព្វហេតុនៃ ការអភិវឌ្ឍធនាគារជាតិនៃកម្ពុជា ឱ្យទទួលបានជោគជ័យថ្មីៗបន្ថែមទៀត និង

៣/- បន្តអនុវត្តនូវ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០** របស់រាជរដ្ឋាភិបាលឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យប្រព្រឹត្តទៅដោយប្រសិទ្ធភាព និងមានលក្ខណៈសមាហរណកម្មជាមួយប្រទេសក្នុងតំបន់និងពិភពលោក ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានខិតខំរួមចំណែកកសាងសមិទ្ធផលយ៉ាងច្រើនសម្រាប់ធនាគារជាតិនៃកម្ពុជា និងកសាងប្រព័ន្ធធនាគារឱ្យទទួលបានជំនឿទុកចិត្តពីសាធារណជនជាតិ

និងអន្តរជាតិ ។ ដើម្បីសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀត ខ្ញុំសូមស្នើសុំឱ្យមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាបន្តស្មារតីរួមសាមគ្គី សហការគ្នាជាប្រពៃណី និងទទួលខុសត្រូវចំពោះការងារ ដើម្បីរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារឱ្យសម្រេចបាននូវសមិទ្ធផលថ្មីៗថែមទៀតនិងកាន់តែមានប្រសិទ្ធភាព ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ។

ឯកឧត្តម ស៊ុំ សន្និសិទ្ធ បានជម្រាបជូនអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗដែលកើតមាននៅខេត្តកំពង់ចាម ដូចជា ឈ្មោះប្រទេសកម្ពុជាដំបូងមានដើមកំណើតចេញពីសិលាចារិកនៅភ្នំហាន់ជ័យ និងការកកើតរូបិយវត្ថុរបស់យើងដំបូងនៅក្នុងសម័យ **ស្តេចកន** គឺ **ព្រះបាទព្រះស្រីជេដ្ឋារាមាធិបតី** ព្រមទាំងរឿងទុំទាវជាដើម ។ ដើម្បីស្វែងយល់ឱ្យបានកាន់តែច្បាស់លាស់ថែមទៀត សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ចាម បានរៀបចំកម្មវិធីទៅទស្សនាតំបន់ប្រវត្តិសាស្ត្រនៅវាំងស្តេចកន បន្ទាប់ពីពិសាអាហារថ្ងៃត្រង់រួច ដូចនេះសូមអញ្ជើញថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិករបស់យើងទាំងអស់គ្នាអញ្ជើញចូលរួម។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតតាំងពីដើមរហូតដល់ចប់ និងសូមជូនពរឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**ខ្ញុំសូមប្រកាសបិទអង្គសន្និបាតរបស់យើងចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ**!